ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣២...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់

~~~~~~~

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណូមពរចាំបាច់

### សំរេច

**មាត្រា ១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ ។

**មាត្រា ២.-**

សមាសភាពនៃក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។
~~~~~~~

មាត្រា៣.-

ក្រុមប្រឹក្សាអ្នកច្បាប់ ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ហើយមានភារកិច្ចដូចតទៅ ÷

-សិក្សាស្រាវជ្រាវ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និង ផ្នែកឯកជន ដើម្បីលើកគំរោងកសាងច្បាប់ ឬ លិខិតបទដ្ឋានថ្មីៗ ដែលមានការចាំបាច់សំរាប់បំរើ អោយសកម្មភាពរាជរដ្ឋាភិបាល

-ទំនាក់ទំនង សំរបសំរួល និងផ្តល់យោបល់ដល់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធនឹងការតាក់តែង ច្បាប់ និងលិខិតបទដ្ឋានអោយស្របតាមអាទិភាពនៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល

-សិក្សា និងតាមដានអត្ថបទច្បាប់ និងលិខិតបទដ្ឋានទាំងឡាយដែលត្រូវបានប្រកាសចេញ អោយប្រើ ដែលលែងសមស្របនឹងសភាពការណ៍ជាក់ស្តែង ដើម្បីលើកយោបល់ជូនរាជរដ្ឋាភិបាល ធ្វើវិសោធនកម្ម អោយទាន់ពេលវេលា និងស្របតាមស្ថានភាពវិវត្តន៍នៃប្រទេសជាតិ

-សិក្សា និងផ្តល់យោបល់ជូនគណៈរដ្ឋមន្ត្រី អំពីសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាន សន្ធិសញ្ញា អនុសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយជាមួយអន្តរជាតិ ដែលបណ្តាក្រសួង ស្ថាប័នផ្ញើមកសុំ សេចក្តីសំរេចពីគណៈរដ្ឋមន្ត្រី

-តាមដាន ឃ្លាំមើលលើការអនុវត្ត និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន

-ជួយទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការសហការជាមួយក្រសួងទំនាក់ទំនងជាមួយព្រឹទ្ធសភា រដ្ឋសភា និងអធិការកិច្ចក្នុងការចាត់ចែងផ្ញើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានទៅជូនស្ថាប័ន ដែល មានសមត្ថកិច្ចផ្តល់សច្ចាប័នជាចុងក្រោយអោយបានសមស្របតាមនីតិវិធី

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទីស្តីការគណៈរដ្ឋមន្ត្រី

-ធ្វើរបាយការណ៍ អំពីសកម្មភាពការងាររបស់ក្រុមប្រឹក្សាអ្នកច្បាប់ តាមកាលកំណត់អោយ បានទៀងទាត់ជូនប្រមុខរាជរដ្ឋាភិបាល ។

មាត្រា៤ .-

-ក្រុមប្រឹក្សាអ្នកច្បាប់ មានអគ្គលេខាធិការដ្ឋានជាជំនួយការ និងមានទីតាំងនៅទីស្តីការ គណៈរដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអ្នកច្បាប់ដឹកនាំដោយអគ្គលេខាធិការមួយរូប ទទួលបន្ទុកកិច្ចការ រដ្ឋបាល ថវិកា និងការរៀបចំ គ្រប់គ្រងឯកសារទូទៅ

-អគ្គលេខាធិការ មានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមានផ្នែកជំនាញមួយចំនួនតាមការចាំបាច់

-អគ្គលេខាធិការរង មានឋានៈស្មើអគ្គនាយក

-ប្រធានផ្នែកជំនាញ មានឋានៈស្មើប្រធាននាយកដ្ឋាន និងមានមន្ត្រីមួយចំនួនជាជំនួយការ ។

**មាត្រា៥ ..**

ក្រុមប្រឹក្សាអ្នកច្បាប់ ធ្វើការប្រជុំតាមសេចក្តីអញ្ជើញរបស់ប្រធាន

ប្រធានអាចអញ្ជើញអ្នកមានសមត្ថកិច្ចផ្សេងៗ នៃក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន អោយចូលមកបំភ្លឺ ចូលរួមកិច្ចប្រជុំការងារ ឬសិក្សាលើឯកសារពាក់ព័ន្ធ

ក្រុមប្រឹក្សាអ្នកច្បាប់ ចូលរួមប្រជុំអន្តរក្រសួង និងសហការជាមួយអគ្គលេខាធិការរាជរដ្ឋាភិបាល ក្នុងកិច្ចការដែលពាក់ព័ន្ធនឹងច្បាប់ លិខិតបទដ្ឋាននានា ដែលក្រសួង ស្ថាប័នបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី

ក្រុមប្រឹក្សាអ្នកច្បាប់ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា៦ ..**

អនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៧ ..**

រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា៧
-ឯកសារ-កាលប្បវត្តិ